# គោលនយោបាយសម្រាប់មូលដ្ឋានគ្រឹះ និងការតាំងចិត្តជាមូលដ្ឋាន
# ជំនឿ និង ការតាំងចិត្តនៃក្រុមប្រឹក្សាគ្រប់គ្រងសាលា PROVIDENCE

## គោលបំណង

ដើម្បីផ្តោតកំណែទម្រង់ និង រចនាសម្ព័ន្ធឲ្យទូលំទូលាយចំពោះសាលារៀនរបស់រដ្ឋនៅ Providence ទៅលើជោគជ័យរបស់សិស្សានុសិស្សទាំងអស់។

## បញ្ហា

ដូចគ្នាទៅនឹងសាលាកំរងទីក្រុងទាំងអស់ដែរនោះ សាលា Providence ប្រឈមទៅនឹងកិច្ចខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញនៅក្នុងសកម្មភាពអប់រំដល់សិស្សានុសិស្សទាំងអស់របស់យើងដើម្បីឈានឆ្ពោះទៅរកជីវិតប្រកបដោយ ជោគជ័យពេញលេញ។ កិច្ចខិតខំប្រឹងប្រែងជាច្រើនអស់ទាំងនេះ ស្ថិតនៅហួសពីសមត្ថភាពរបស់យើង ហើយចាំបាច់ត្រូវមានការផ្លាស់ប្តូរនានានៅក្នុងបញ្ហាគោលនយោ បាយសាធារណៈ។ ប៉ុន្តែយើងនឹងប្រើប្រាស់នូវអ្វីដែលហួសពីសមត្ថភាពត្រួតត្រារបស់យើង ថាជា◌េលសមួយក្នុងការមិនធ្វើអ្វីៗគ្រប់យ៉ាងដែលស្ថិតក្រោមការត្រួតត្រាការងាររបស់យើងនោះទេ។

សាលារៀននៅតាមទីក្រុង មានឱកាស និង កាតព្វកិច្ចពិសេសមួយដាច់ដោយឡែកដើម្បីជួយដល់សិស្សានុសិស្សគ្រប់ៗគ្នា – ដោយមិនគិតពីជាតិសាសន៍ កម្រិតប្រាក់ចំណូល ការទ្រទ្រង់របស់ក្រុមគ្រួសារ ភាសាទី១ ឬ សារប្រយោជន៍សិក្សាអប់រំជាអាទិភាព – ដើម្បីយល់ដឹងពីក្តីសុបិន្តរបស់ជនជាតិអាមេរិកាំង។ យើង ក្រសោបយកឱកាស និង កាតព្វកិច្ចនោះ។ ការសិក្សាអប់រំ គឺជាសិទ្ធិមួយ។ យើង ប្រកាន់យកយ៉ាងហ្មត់ចត់នូវកាតព្វកិច្ចប្រកបដោយសីលធម៌របស់យើងដើម្បីដឹងថាសិស្សគ្រប់ៗរូបទទួលបាននូវការអប់រំដែលជាសិទ្ធិរបស់ពួកគេ។

សាលារដ្ឋដែលមិនដូចជាសាលាឯកជននោះ មិនជ្រើសរើសយកអ្នកដែលត្រូវបម្រើទេ។ យើងបម្រើសិស្សទាំងអស់របស់យើង – ទាំងអ្នកមាន និង អ្នកក្រ ភាគតិច និង ភាគច្រើន សិស្សដែលក្រុមគ្រួសាររបស់គេបានត្រៀមរៀបចំសម្រាប់ពួកគេបានយ៉ាងល្អសម្រាប់សាលា និង សិស្សដែលមិនដែលចូលរៀន សិស្សដែលក្រុមគ្រួសាររបស់ពួកគេបានក្លាយទៅជាជំនាន់ពាក់ព័ន្ធច្រើនជំណរមកហើយ និង សិស្សដែលទើបតែមកដល់ថ្មី។ ប្រជាពលរដ្ឋចម្រុះរបស់យើង បានធ្វើឲ្យយើងខិតខំអស់ពីសមត្ថភាពរបស់យើងដើម្បីបម្រើសិស្សានុសិស្ស និង ក្រុមគ្រួសាររបស់ពួកគេដែលពីមុនមកមិនធ្លាប់មាន។ ប៉ុន្តែយើងអោយតម្លៃពហុភាពរបស់យើងជារតនៈសម្បត្តិមួយៈ សិស្សរបស់យើងទទួលបានអត្ថប្រយោជន៍នៅពេលដែលពួកគេសិក្សារៀនសូត្រទាំងអស់គ្នា និង ពីគ្នាទៅវិញទៅមក។

សាលានានារបស់យើង អាច និង ត្រូវតែមានភាពខុសគ្នាយ៉ាងច្រើននៅក្នុងដំណើរជីវិតរបស់សិស្សយើង ក៏ប៉ុន្តែពួកគេមិនអាចធ្វើទៅតែឯងបានទេ។ សហគមន៍ទាំងមូល – សាលារៀន តំបន់ ក្រុមគ្រួសារ ដៃគូ ក្រុមហ៊ុន – មានទំនួលខុសត្រូវរួមសម្រាប់ជោគជ័យរបស់សិស្សយើង។ សាលានានារបស់យើង ត្រូវតែបម្រើឲ្យសហគមន៍របស់យើង ហើយសហគមន៍របស់យើងត្រូវតែគាំទ្រសាលារៀនរបស់យើងដែរ។ ការគាំទ្ររបស់សាលាចំពោះសហគមន៍ និង ការគាំទ្ររបស់សហគមន៍ចំពោះសាលា បង្កើននូវទុនសង្គម និង ជោគជ័យដោយផ្ទាល់របស់សិស្សយើង។

អស់ពេលជាយូរមកហើយ សាលារបស់យើងបានធ្វើឲ្យសិស្សរបស់យើងច្រើនណាស់ខកចិត្ត ហើយបាននាំឲ្យមានសម្រាប់ពួកគេទាំងនោះ នូវមធ្យោបាយ និង ជម្រើសផ្សេងៗទៀត។ ការបំពេញតួនាទី បានធ្វើឲ្យប្រសើរឡើងវិញលើរយៈពេលប្រាំឆ្នាំមកហើយ ប៉ុន្តែសិស្សរបស់យើងបន្តអនុវត្តន៍ការសិក្សារៀនសូត្ររបស់ខ្លួនក្នុងកម្រិតទាបបំផុតនៅទូទាំងប្រទេស ហើយភាពមិនស៊ីសង្វាក់គ្នាដោយបញ្ហាជាតិសាសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គម និង បញ្ហាភាសាទី១ នៅតែមាន។ ក្រុមប្រឹក្សាគ្រប់គ្រងសាលា Providence ត្រូវបានកំណត់ឡើងប្រយោជន៍ផ្លាស់ប្តូរបញ្ហានោះ។ សាលារៀននានានៅទីក្រុង Providence ត្រូវតែក្លាយទៅជាសាលានៃជម្រើសទី១ មិនមែនជាប្រភេទជំរើសចុងក្រោយនោះទេ សម្រាប់ក្រុមគ្រួសារយើងទាំងអស់គ្នា។

គុណតម្លៃស្នូល
គោរព សមធម៌ ភាពប្រពៃ គណនេយ្យភាព និង ការផ្តល់តម្លៃដល់ពហុភាពរបស់យើង។

ទស្សនៈវិស័យ
សាលារដ្ឋនៅ Providence នឹងក្លាយជាសាលាឈានមុខគេថ្នាក់ជាតិមួយនៅក្នុងវិស័យអប់រំសិក្សាធិការសម្រាប់យុវជននៅតាមទីក្រុង។

បេសកកម្ម
សាលារៀននានានៅ Providence នឹងរៀបចំឲ្យសិស្សទាំងអស់ទទួលបានជោគជ័យនៅតាមមហាវិទ្យាល័យ និង សាកលវិទ្យាល័យ និង តាមវិជ្ជាជីវៈរបស់ពួកដែលបានជ្រើសរើសយក។

ជំនឿ និង ការតាំងចិត្ត
1. យើងជឿជាក់ថា សិស្សរបស់ Providence ទាំងអស់អាច និង ត្រូវតែសិក្សារៀនសូត្រនៅកម្រិតខ្ពស់ សម្រេចបាននូវសក្តានុពលពេញលេញរបស់ខ្លួន និង ទទួលបានជោគជ័យទាំងនៅសាលា និង ក្នុងជីវិត។

យើងជឿថា—
- ✓ សក្តានុពលសិក្សារៀនសូត្រ គឺមិនមែនមានជាប់ពីកំណើត និង បញ្ហាជាតិសាសន៍ ឬ ស្ថានភាពសេដ្ឋកិច្ចសង្គមនោះទេ គឺវាវិវឌ្ឍទៅតាមពេលវេលាដែលមានឱកាស កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់អស់ពីសមត្ថភាព។
- ✓ ជោគជ័យរួមមានមិនត្រឹមតែការសម្រេចបាននូវលទ្ធផលនៃការសិក្សានោះទេ តែថែមទាំងការអភិវឌ្ឍន៍ផ្នែកសង្គម ផ្លូវចិត្ត រូបវន្ត ចិត្តសាស្ត្រ និង សីលធម៌ថែមទៀតផងដែរ។
- ✓ ជោគជ័យ មានន័យដល់ការរួមវិភាគទានដល់សង្គមរបស់យើង និង ការចូលរួមនៅក្នុងបញ្ហាជីវភាពប្រជាពលរដ្ឋ។
- ✓ សាលា ត្រូវតែបណ្តុះឲ្យមាននូវសេចក្តីស្រឡាញ់សម្រាប់ការសិក្សារៀនសូត្រ បង្រៀនសិស្សនូវរបៀបសិក្សាស្វែងយល់ និង ជួយសិស្សឲ្យអភិវឌ្ឍនូវទេពកោសល្យរបស់ខ្លួន។
- ✓ ភាពមិនស៊ីសង្វាក់គ្នាជាច្រើននៅក្នុងការសម្រេចបានជោគជ័យលើការសិក្សាជាមួយនឹងខ្សែស្រឡាយជាតិសាសន៍ និង សេដ្ឋកិច្ច មានលក្ខណៈអត់ទ្រាំបានដោយគិតទៅតាមសីលធម៌។
- ✓ សេចក្តីណែនាំរបស់អ្នកជំនាញការ ពេលវេលាគ្រប់គ្រាន់ និង ការជួយទំនុកបម្រុងត្រឹមត្រូវ អាចជួយឲ្យសិស្សគ្រប់រូបទទួលបានជោគជ័យ។

យើង តាំងចិត្តចំពោះការបង្កើតឲ្យមានលក្ខខ័ណ្ឌនានាសម្រាប់សិស្សគ្រប់រូបសិក្សាស្វែងយល់អោយ បានដល់កម្រិតខ្ពស់ និង អស់ពីសក្តានុពលរបស់ពួកគេ។ យើងតាំងចិត្តចំពោះការបំពេញនូវកង្វះខាតសម្រាប់ការសម្រេចបានជោគជ័យ។
យើង នឹង—

- ✓ ខិតខំឲ្យអស់ពីសមត្ថភាពសម្រាប់សិស្សរបស់យើង និង ទ្រទ្រង់ពួកគេទាំងអស់គ្នាសម្រាប់រំពឹងទុកច្បាស់លាស់ និង ក្នុងកម្រិតខ្ពស់ដូចគ្នា។
- ✓ បង្កើតឲ្យមានជាសហគមន៍សិក្សាស្វែងយល់រស់រវើកជាមួយនឹងបណ្តាកាលានុវត្តភាពនានាសម្រាប់ការសិក្សាដ៏ខ្លាំងក្លា ជាកម្មវិធីរួម និង មាននិស្សារណៈកម្ម។
- ✓ វាស់កម្រិតជោគជ័យរបស់សិស្សតាមរយៈមុខវិជ្ជាដែលបានរៀនសូត្រ ដោយមិនគិតត្រឹមតែកម្មវិធីដែលបានរៀបចំឡើងសម្រាប់ការបង្រៀនតែប៉ុណ្ណោះទេ។
- ✓ ផ្តល់ឲ្យសិស្សនូវបណ្តាកាលានុវត្តភាព និង ជំរើសដែលនឹងទទួលបានជោគជ័យ។
- ✓ បង្កើតឡើងនូវកាលានុវត្តភាពរបស់សាលាប្រកបដោយការជឿទុកចិត្ត និង ពោរពេញទៅដោយក្តីគោរព។
- ✓ លើកកម្ពស់បញ្ហាសុខភាពអនាម័យរបស់សិស្ស។
- ✓ បង្កើតឲ្យមាននូវដៃគូជាយុទ្ធសាស្ត្រដោយមានអង្គការនានាពីខាងក្រៅចូលរួមលើកកម្ពស់តម្លៃនៃការជួយឧបត្ថម្ភគាំទ្រដល់សិស្ស។

2. យើង ជឿជាក់ថា លោកគ្រូអ្នកគ្រូនៃសាលា Providence រួមជាមួយនិងសាលា អាច និង ត្រូវតែមានឥទ្ធិពលជាវិជ្ជមាន និង មានអានុភាពក្នុងលក្ខណៈស៊ីជម្រៅទៅលើដំណើរជីវិតសិស្សរបស់ខ្លួន។
យើង ជឿជាក់ថា—

- ✓ ទំនាក់ទំនាក់គ្រូ និង សិស្ស គឺផ្តោតលើសកម្មភាពសិក្សាស្វែងយល់។
- ✓ គ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព ទទួលយកនូវទំនួលខុសត្រូវសម្រាប់អ្វីដែលកើតមានឡើងនៅក្នុងថ្នាក់រៀន និង បញ្ហាគណនេយ្យភាពសម្រាប់អ្វីដែលសិស្សម្នាក់ៗសិក្សាស្វែងយល់។
- ✓ ដោយផ្ទាល់ វាគឺជាគ្រូដែលបង្កើតនូវភាពខុសគ្នារវាងជោគជ័យ និង បរាជ័យរបស់សិស្ស។
- ✓ សាលារៀននានា ស្ថិតនៅគាំទ្រដល់ទំនាក់ទំនងគ្រូ និង សិស្ស ហើយតំបន់ស្ថិតនៅគាំទ្រដល់សាលាវិញដែរ។

យើង តាំងចិត្តចំពោះការរៀបចំសាលារបស់យើង និង ធនធានទាំងអស់របស់យើងប្រយោជន៍ជួយឧបត្ថម្ភគាំទ្រដល់ទំនាក់ទំនងរវាងគ្រូ និង សិស្សនូវកត្តាជាចម្បងលើជោគជ័យរបស់សិស្សានុសិស្ស។

យើង នឹង—

- ✓ មានលោកគ្រូអ្នកគ្រូប្រកបដោយប្រសិទ្ធភាពខ្ពស់នៅគ្រប់ថ្នាក់។
- ✓ មានមេដឹកនាំស្ថាប័នម្នាក់ដែលរឹងមាំ និង ជានាយក ឬ បង្គោលនៅគ្រប់សាលារៀន។
- ✓ ដាក់ចេញនូវគោលនយោបាយ និង បែងចែកធនធាន ដោយមានសំណើរបៀបដែលសេចក្តីសម្រេចចិត្តរបស់យើងជួយដល់ការសិក្សាស្វែងយល់របស់សិស្ស។

3. យើង ជឿជាក់ថាសាលានានាប្រចាំនៅ Providence អាច និង ត្រូវតែជាកន្លែងដ៏ល្អដើម្បីបង្រៀន និង សិក្សាស្វែងយល់។

យើង ជឿជាក់ថា—

- ✓ សាលារៀននានា ត្រូវតែមានសុខសុវត្ថិភាព ការយកចិត្តទុកដាក់ និង បរិយាកាសមានសណ្ដាប់ធ្នាប់ដែលបណ្ដុះនូវការបង្ហាត់បង្រៀន និង សិក្សាស្វែងយល់ប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ✓ សាលារៀននានា ត្រូវផ្ដល់នូវតម្លៃពហុភាពរវាងសិស្សានុសិស្ស បុគ្គលិក និង ក្រុមគ្រួសារសិស្ស។
- ✓ សិស្សានុសិស្ស បុគ្គលិក ដៃគូ និង ដៃគូសហគមន៍ ត្រូវតែបង្ហាញឲ្យឃើញច្បាស់នូវឥរិយាបថមិនរើសអើងប្រកបដោយសីលធម៌ និង ពោរពេញទៅដោយការពិត។

យើង តាំងចិត្តចំពោះការបង្កើតឲ្យមាននូវសាលារៀននានាដែលមានវប្បធម៌នានាជាវិជ្ជមាន ហើយដាក់ឲ្យស្ថិតនៅជាមធ្យោបាយការងារប្រកបដោយគុណភាពខ្ពស់របស់សាលារៀន។

យើង នឹង—

- ✓ បន្តរក្សានូវភាពទាក់ទាញ មានអនាម័យ និង ធានាបាននូវសន្តិសុខសុវត្ថិភាពសាលា។
- ✓ ធ្វើឲ្យមានការវិវឌ្ឍន៍ថ្មី ឬ ដាក់ជំនួសនូវអគារសិក្សាថ្មីដែលសំខាន់ចាំបាច់សម្រាប់ដាក់ឲ្យមាននូវការសិក្សារៀនសូត្រសម្រាប់សតវត្សទី២១ និង បម្រើជាវង្វាន់ដល់កិច្ចខំប្រឹងប្រែងរបស់សហគមន៍។
- ✓ ទ្រទ្រង់សិស្ស បុគ្គលិក មាតាបិតាអាណាព្យាបាល និង ដៃគូរនៅតាមសហគមន៍ចំពោះបទដ្ឋានកម្រិតខ្ពស់នៃការប្រព្រឹត្តទៅ។

4. យើង ជឿជាក់ថាតំបន់សាលារៀននៅ Providence អាច និង ត្រូវតែជាអង្គការបំពេញមុខងារមានប្រសិទ្ធភាពខ្ពស់មួយ។

យើង ជឿជាក់ថា—

- ✓ មនុស្ស និង កម្មវត្ថុនិងគោលបំណង ដឹកនាំទៅរកការអនុវត្តន៍តួនាទីប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ✓ យើង ត្រូវតែចាប់យកនូវជម្រៅទឹកចិត្តនៃមនុស្សរបស់យើងដែលមានទស្សនៈច្បាស់លាស់ និង រស់រវើកសម្រាប់ជោជ័យរបស់សិស្សដែលមានដូចជាកាលានុវត្តភាពនានាសម្រាប់ការចូលរួម កិច្ចសហការ ការងារជាក្រុម និង ការធ្វើសេចក្ដីសម្រេចចិត្តរួម។
- ✓ យើង ត្រូវមានភាពជាអ្នកដឹកនាំប្រកបដោយទស្សនៈ និង មានការបែងចែកច្បាស់លាស់ និង ការផ្ដោតយ៉ាងមុតមាំលើលទ្ធផល។
- ✓ យើង ត្រូវតែផ្ដល់នូវលទ្ធផលដែលអាចវាយតម្លៃបានជំនួសឲ្យការតាំងចិត្តចំពោះធនធានសាធារណៈ។

យើង តាំងចិត្តចំពោះការរៀបចំមន្ទីរសាលានៅ Providence នៅជុំវិញបញ្ហាការងារសំខាន់របស់វា – ការបង្រៀន និង សិក្សាស្វែងយល់។

យើង នឹង—

- ✓ ទ្រទ្រង់ដល់តំបន់ទាំងមូល និង គ្រប់ៗគ្នានៅក្នុងបញ្ហានេះ ដែលមានន័យកំណត់នូវជោគជ័យរបស់សិស្ស។
- ✓ ផ្ដោតគោលដៅលើធនធាននានាទៅលើអាទិភាពនានារបស់តំបន់។

- ✓ ជ្រើសរើស អភិវឌ្ឍ គាំទ្រ និង បន្តរក្សាទុកនូវបុគ្គលិកគ្រូបង្រៀនដែលមានគុណភាពខ្ពស់បំផុត។
- ✓ ធ្វើប្រតិបត្តិការលើប្រព័ន្ធស្ថាប័ន និង ការងារប្រកបដោយប្រសិទ្ធភាព។
- ✓ ប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព។

5. យើង ជឿជាក់ថា មាតាបិតាអាណាព្យាបាលសិស្សនៅ Providence និង សហគមន៍ Providence ទាំងមូល អាច និង ត្រូវតែគាំទ្រដល់ជោគជ័យនៃសិស្សរបស់យើង។

យើង មានជំនឿជាក់ថា—
- ✓ មាតាបិតាអាណាព្យាបាលសិស្ស គឺជាគ្រូទី១នៃសិស្សានុសិស្សរបស់យើង។
- ✓ សហគមន៍របស់យើង មាននូវធនធាននានានៃវប្បធម៌ដ៏សម្បូណ៌បែបដើម្បីជួយគាំទ្រដល់ការអប់រំសិក្សាធិការរបស់យើង។
- ✓ ប្រព័ន្ធ និង សហគមន៍សាលារៀន កម្រិតនូវទំនួលខុសត្រូវទៅវិញទៅមកសម្រាប់បញ្ហាជោគជ័យរបស់សិស្ស។

យើង តាំងចិត្តចំពោះការធ្វើជាដៃគូជាមួយមាតាបិតាអាណាព្យាបាល និង សហគមន៍នៅក្នុងការធ្វើឲ្យចេញជារូបរាងជាក់ស្តែង និង ផ្តល់ការគាំទ្រលើបញ្ហាការសិក្សាអប់រំនៃសិស្សរបស់យើង។

យើង នឹង
- ✓ ស្វាគមន៍ និង ភ្ជាប់ទំនាក់ទំនងជាមួយមាតាបិតាអាណាព្យាបាលសិស្ស និង សហគមន៍ដែលជាដៃគូ និង អ្នកគាំទ្រដ៏មានតម្លៃសម្រាប់បញ្ហាអប់រំសិក្សាធិការ។
- ✓ បង្កើតនូវការប្រាស្រ័យទាក់ទងគ្នារវាងសាលារៀន និង មាតាបិតាអាណាព្យាបាលសិស្ស តាមរយៈការផ្តល់ឲ្យនូវវិធីនានាប្រកបដោយមិត្តភាពសម្រាប់មាតាបិតាអាណាព្យាបាលសិស្សទាក់ទងមកសាលា និង តាមរយៈការប្រាស្រ័យទាក់ទងជាមួយមាតាបិតាអាណាព្យាបាលជាភាសាច្បាស់លាស់ និង ចំគោលដៅ។
- ✓ ផ្តល់នូវលំដាប់លំដោយវិធីសាស្ត្រសម្រាប់មាតាបិតាអាណាព្យាបាលដើម្បីចូលរួមនៅក្នុងបញ្ហាការអប់រំសិក្សាធិការនៃកូនៗរបស់ខ្លួននៅផ្ទះ និង នៅសាលារៀន។
- ✓ បង្កើតភាពជាដៃគូជាមួយសហគមន៍ប្រយោជន៍ភ្ជាប់ទំនាក់ទំនងសាលារៀន សិស្សានុសិស្ស និង មាតាបិតាអាណាព្យាបាលសិស្សជាមួយនឹងធនធានរបស់សហគមន៍។

កំណត់ហេតុទិន្នានុប្បវត្តិៈ ដំណោះស្រាយលេខ 11-22-04 ចុះថ្ងៃទី22 វិច្ឆិកា 2004
ការធ្វើវិសោធនកម្មៈ ដំណោះស្រាយលេខ 12-16-06 ចុះថ្ងៃទី11 ធ្នូ 2006
បានពិនិត្យឡើងវិញនៅៈ ថ្ងៃទី24 មករា 2008